# បណ្ណបញ្ជូនជំនួយ តាមប្រព័ន្ធ អេឡិកត្រូនិក (EBT) រដ្ឋកាលីហ្វ័រនីញ៉ា




## ជាវិធីមួយដែលងាយ សន្តិសុខ ស្រួល ដើម្បីទទួលបណ្ណទិញម្ហូប និងប្រាក់ជំនួយរបស់លោកអ្នក

*សូមរក្សាទុកកូនសៀវភៅនេះនៅកន្លែងដែលមានសុវត្ថិភាព*

តើមានសំណួរឬទេ? សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជនដោយឥតគិតថ្លៃ ធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍

**1-877-328-9677 ឬ**
**www.ebt.ca.gov**

TTY: 1-800-735-2929 (ប្រព័ន្ធទូរស័ព្ទបញ្ជូនបន្តសំរាប់លោកអ្នកដែលមានភាពពិការក្នុងការស្តាប់និងការនិយាយ)

*បន្ទាប់ពីបានអានកូនសៀវភៅនេះរួចហើយ។លោកអ្នក
នៅមានបំណងចង់ទទួលយកការបង្ហាត់បង្រៀនជាបន្ថែមទៀត
សូមទាក់ទងទៅអ្នកកាន់សំណុំរឿងរបស់លោកអ្នក ។*

# ពាក្យខ្លះៗដែលគួរដឹង

## ម៉ាស៊ីនPOS (Point-of-Sale)



ម៉ាស៊ីន POS ដែលពិនិត្យប័ណ្ណ EBT របស់លោកអ្នក រួចអនុញ្ញាតឱ្យលោកអ្នកទិញម្ហូបអាហារដោយប្រើជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក ។ លោកអ្នកអាចទិញម្ហូបអាហារ ឬរបស់មិនមែនជាម្ហូបអាហារ និងដកយកប្រាក់ដោយប្រើការទិញជាមួយប្រាក់ជំនួយរបស់លោកអ្នក នៅតាមហាងលក់ទំនិញខ្លះ ។ មានហាងទំនិញខ្លះក៏អាចអនុញ្ញាតឱ្យលោកអ្នកដកយកប្រាក់នៅតាមម៉ាស៊ីនPOS ដោយមិនចាំបាច់ទិញផងដែរ ។

## ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិATM

(Automated Teller Machine)



ម៉ាស៊ីន ATM គឺជាម៉ាស៊ីនដកប្រាក់ដែលមាននៅតាមធនាគារ ហាងលក់ទំនិញ និងទីកន្លែងជាច្រើនទៀត ដែលអនុញ្ញាតឱ្យលោកអ្នកដកយកប្រាក់ជំនួយរបស់លោកអ្នក ។

## លេខសម្ងាត់PIN (Personal Identification Number)

លេខសម្ងាត់ PIN មានបួនខ្ទង់ដែលលោកអ្នកប្រើជាមួយប័ណ្ណ EBT របស់លោកអ្នក ដើម្បីឱ្យប្រាកដថាមានតែលោកអ្នកម្នាក់អាចប្រើប័ណ្ណរបស់លោកអ្នក ។ ម៉ាស៊ីន POS នឹងប្រើការមិនបានឡើយលុះត្រាតែលោកអ្នកចុចបញ្ចូលលេខសម្ងាត់ PIN របស់លោកអ្នក ។ គឺជាការសំខាន់ណាស់ដែលលោកអ្នកត្រូវរៀនឱ្យបានចាំលេខសម្ងាត់ PIN របស់លោកអ្នក ។ នេះគឺជារបៀបលេខសម្ងាត់ PIN របស់លោកអ្នកបង្ហាញនៅលើម៉ាស៊ីន POS ។

*** * * ***

## សញ្ញាQuest®

សញ្ញា Quest® គឺជាផ្លាកសញ្ញាដែលលោកអ្នកនឹងឃើញគេបិទបង្ហាញនៅតាមទ្វារហាងលក់ទំនិញ ផ្សារកន្លែងគិតថ្លៃទំនិញ និងម៉ាស៊ីន POS ដែលអាចឱ្យលោកអ្នកដឹងថា លោកអ្នកអាចប្រើប័ណ្ណ EBT នៅតាមហាងលក់ទំនិញឬម៉ាស៊ីននោះ ។ នៅលើសញ្ញា Quest® គឺមានរូបភាពពិសេសមួយដែលបង្ហាញថាជំនួយមួយណាដែលលោកអ្នកអាចប្រើដើម្បីទិញ ។ សូមស្វែងរកសញ្ញា Quest® និងរូបភាពទាំងនេះនៅតាមហាងលក់ទំនិញ នៅមុនពេលលោកអ្នកទិញទំនិញ ។

QUEST®

# ទីកន្លែងដែលអាចប្រើប័ណ្ណ EBT របស់លោកអ្នក

គ្រប់ទីកន្លែងណាដែលលោកអ្នកឃើញមានសញ្ញា Quest® ទូទាំងរដ្ឋកាលីហ្វ័រនីញ៉ា និងទូទាំងប្រទេស។

# លោកអ្នកអាចប្រើប័ណ្ណ EBT របស់លោកអ្នកនៅតាមៈ

**ម៉ាស៊ីនPOS ដើម្បី :**



- ប្រើជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក ដើម្បីទិញម្ហូបអាហារ
- ប្រើប្រាក់ជំនួយរបស់លោកអ្នកដើម្បីទិញម្ហូបអាហារ ឬ របស់មិនមែនជាម្ហូបអាហារ ដូចជាកន្ទបទារក និងសំលៀកបំពាក់
- ដកហូតយកប្រាក់ចេញពីគណនីប្រាក់របស់លោកអ្នក បន្ទាប់ពីពេលអ្នកបានទិញទំនិញរួច (អាស្រ័យទៅលើច្បាប់នៃហាងទំនិញនោះ)
- ដកហូតយកប្រាក់ចេញពីគណនីប្រាក់របស់លោកអ្នក ដោយមិនបាច់ទិញទំនិញ (អាស្រ័យទៅលើច្បាប់នៃហាងទំនិញនោះ)



**ម៉ាស៊ីនATM ដើម្បីដកយកប្រាក់ជំនួយរបស់លោកអ្នក**

**លោកអ្នកនឹងរកឃើញម៉ាស៊ីន POS និង/ឬម៉ាស៊ីន ATM នៅតាម:**

- ហាងលក់គ្រឿងធ្វើម្ហូប
- ហាងលក់ទំនិញងាយៗ
- ហាងលក់សំាង
- ហាងលក់ទំនិញធំៗ
- ធនាគារ

# អំពីលេខសម្ងាត់ PIN របស់លោកអ្នក

- លេខសម្ងាត់បួនខ្ទង់របស់លោកអ្នក ត្រូវបានគេហៅថា Personal Identification Number ឬ ជាពាក្យខ្លីហៅថា PIN ។
- រៀងរាល់ពេលណាដែលលោកអ្នកប្រើប័ណ្ណ EBT របស់លោកអ្នក លោកអ្នកនឹងត្រូវការប្រើលេខសម្ងាត់ PIN របស់លោកអ្នក បើមិនដូច្នេះទេប័ណ្ណរបស់លោកអ្នកនឹងប្រើការមិនបាន ហើយលោកអ្នកនឹងមិនអាចដកយកប្រាក់ជំនួយរបស់លោកអ្នកបានឡើយ ។

* * * *

- គ្មានអ្នកណាដឹងលេខសម្ងាត់ PIN របស់លោកអ្នកឡើយ ។ នេះរាប់បញ្ចូលទាំងអ្នកកាន់សំណុំរឿងរបស់លោកអ្នក និងអ្នកតំណាងផ្ដល់កិច្ចបំរើអតិថិជនតាមទូរស័ព្ទ ។

# របៀបរក្សាការពារលេខសម្ងាត់ PIN របស់លោកអ្នកដោយសុវត្ថិភាព

- សូមកុំសរសេរលេខសម្ងាត់ PIN របស់លោកអ្នកនៅលើប័ណ្ណរបស់លោកអ្នក ស្រោមប័ណ្ណ ឬនៅលើរបស់ឯទៀតដែលលោកអ្នករក្សាទុកជាមួយប័ណ្ណរបស់លោកអ្នក ។
- សូមរក្សាទុកលេខសម្ងាត់ PIN របស់លោកអ្នកជាការសម្ងាត់ ។ លោកអ្នកមិនត្រូវប្រាប់លេខសម្ងាត់ PIN របស់លោកអ្នកទៅអ្នកកាន់សំណុំរឿងរបស់លោកអ្នក សមាជិកគ្រួសារ អ្នកគិតប្រាក់នៅហាងទំនិញ ឬអ្នកដទៃទៀតទេ លើកលែងតែលោកអ្នកចង់ឱ្យអ្នកទាំងនោះអាចទទួលនូវជំនួយទាំងអស់របស់លោកអ្នក ។

- សូមកុំប្រើលេខសម្ងាត់ PIN របស់លោកអ្នក ប្រសិនបើលោកអ្នកគិតថាមាននរណាម្នាក់កំពុងតែឃ្លាំមើលលោកអ្នក ។
- នៅពេលលោកអ្នកប្រើប័ណ្ណ EBT របស់លោកអ្នក លោកអ្នកមានឱកាសបួនដង ដើម្បីចុចបញ្ចូលលេខសម្ងាត់ PIN របស់លោកអ្នក ។ បើសិនជាលោកអ្នកចុចលេខសម្ងាត់មិនត្រឹមត្រូវនៅលើកទីបួន លោកអ្នកនឹងមិនអាចប្រើប័ណ្ណរបស់លោកអ្នកបានទៀតឡើយ រហូតទាល់តែបន្ទាប់ពីពេលពាក់កណ្តាលអាធ្រាត្រ ។ បើសិនជាលោកអ្នកមិនអាចចាំលេខសម្ងាត់ PIN របស់លោកអ្នកទេ សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជន (លេខទូរស័ព្ទមានចុះនៅខាងក្រោយនៃប័ណ្ណរបស់លោកអ្នក) ។ អ្នកបំរើអតិថិជនមិនដឹងលេខសម្ងាត់ PIN របស់លោកអ្នកទេ ក៏ប៉ុន្តែគេនឹងជួយលោកអ្នកប្តូរលេខសម្ងាត់ PIN របស់លោកអ្នក ។
- បើសិនជាមានអ្នកណាម្នាក់ដឹងលេខសម្ងាត់ PIN របស់លោកអ្នកដោយគ្មានការអនុញ្ញាតពីលោកអ្នក សូមទូរស័ព្ទទៅអ្នកបំរើអតិថិជនជាបន្ទាន់ ឬអញ្ជើញទៅកាន់ការិយាល័យផ្តល់ជំនួយសាធារណៈដើម្បីប្តូរលេខសម្ងាត់ PIN របស់លោកអ្នក ។
- បើសិនជាមានអ្នកណាម្នាក់យកប័ណ្ណរបស់លោកអ្នក និងដឹងលេខសម្ងាត់ PIN របស់លោកអ្នក អ្នកនោះអាចប្រើជំនួយរបស់លោកអ្នក! បើសិនជាជំនួយរបស់លោកអ្នកត្រូវបានគេដកយកនៅមុនពេលលោកអ្នកទូរស័ព្ទ ទៅផ្នែកបំរើអតិថិជន **ជំនួយនោះនឹងមិនត្រូវបានផ្តល់សងវិញឡើយ** ។ សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជនជាបន្ទាន់ដើម្បីលុបចោលប័ណ្ណរបស់លោកអ្នក ។

# ដឹងអំពីចំនួនប្រាក់នៅសល់ក្រោយពីការចំណាយ

វិធីដ៏ប្រសើរបំផុតដើម្បីដឹងចំនួននៅមានសំរាប់ចាយក្នុងគណនីប័ណ្ណទិញម្ហូបនិង/ឬប្រាក់ជំនួយគឺត្រូវដឹងចំនួននៅសល់ក្រោយពីការចំណាយរបស់លោកអ្នក ។ វិធីដ៏ប្រសើរបំផុតដើម្បីដឹងចំនួននៅសល់ចុងក្រោយ គឺត្រូវរក្សាទុកបង្កាន់ដៃចុងក្រោយរបស់លោកអ្នក ។



STORE NAME
100 ANY STREET ADDRESS
CITY, STATE ZIP

TERM ID 258407
MERCH TERM ID 258407ABC
SEQ# 289
CLERK 107
06/02/99 10:25
CASE # C1234567890

| | TRAN AMT | END BAL |
|---|---|---|
| CASH | $ 0.00 | $ 125.00 |
| FS | $ 45.20 | $ 229.80 |

FS PURCH $ 45.20 APPROVED

*** DO NOT DISPENSE CASH ***

បើសិនជាលោកអ្នកបាត់បង្កាន់ដៃចុងក្រោយរបស់លោកអ្នក ហើយលោកអ្នកត្រូវការចង់ដឹងចំនួនជំនួយនៅសល់ក្រោយពីការចំណាយរបស់លោកអ្នក :

- សូមទូរស័ព្ទទៅលេខផ្នែកបំរើអតិថិជនដែលមាននៅផ្នែកខាងក្រោយនៃប័ណ្ណរបស់លោកអ្នក ឬ
- ឆែកមើលចំនួននៅសល់ក្រោយពីចំណាយនៃគណនីប័ណ្ណទិញម្ហូបរបស់លោកអ្នកនៅម៉ាស៊ីន POS ឬ
- ឆែកមើលចំនួននៅសល់ក្រោយពីចំណាយនៃគណនីប័ណ្ណទិញម្ហូបនិង/ឬប្រាក់ជំនួយតាមទំព័រអ៊ិនធឺណិតនៃ EBT អាសយដ្ឋាន www.ebt.ca.gov ។
- ឆែកមើលចំនួននៅសល់នៃគណនីប្រាក់របស់លោកអ្នកតាមម៉ាស៊ីន ATM ឬម៉ាស៊ីន POS ។ (បើសិនជាលោកអ្នកឆែកមើលចំនួននៅសល់ក្រោយពីចំណាយតាមមាស៊ីន ATM លោកអ្នកនឹងត្រូវបង់ថ្លៃឈ្នួល 25 សេន ។)

**លោកអ្នកគួរតែដឹងអំពីចំនួននៅសល់ក្រោយពីការចំណាយរបស់លោកអ្នក នៅមុនពេលប្រើប័ណ្ណរបស់លោកអ្នក!**

# របៀបប្រើប័ណ្ណ EBT របស់លោកអ្នកនៅតាមម៉ាស៊ុន Point-of-Sale (POS) Machine

ជំហានដែលលោកអ្នកត្រូវធ្វើតាមអាចខុសគ្នាទៅតាមប្រភេទនៃម៉ាស៊ុន POS នីមួយៗដែលលោកអ្នកប្រើ ។ សូមកុំញញើតនឹងស្នើសុំជំនួយពីអ្នកគិតប្រាក់ ។

## ដើម្បីទិញម្ហូបអាហារតាមម៉ាស៊ុន POS :



លោកអ្នកត្រូវដឹងអំពីចំនួននៅសល់ក្រោយពីការចំណាយរបស់លោកអ្នក! សូមផែកមើលបង្កាន់ដៃចុងក្រោយ ឬទូរស័ព្ទទៅផ្នែកបំរើអតិថិជននៅមុនពេលទិញទំនិញ ឬលោកអ្នកអាចឆែកមើលចំនួននៅសល់ក្រោយពីការចំណាយតាមប្រព័ន្ធអ៊ិនធឺណិត www.ebt.ca.gov ។

**ជំហានទី1** ជ្រើសរើសទំនិញម្ហូបអាហាររបស់លោកអ្នក ហើយនាំទៅកាន់ជួរគិតប្រាក់ ។ អាស្រ័យទៅលើហាងទំនិញ លោកអ្នកអាចត្រូវបែងចែកទំនិញជាម្ហូបដែលមានសិទ្ធិទិញដោយឡែកពីមុខរបស់ដែលលោកអ្នកមិនមានសិទ្ធិទិញ ។

**ជំហានទី2** ឆូតប័ណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីនចំណុចលក់ទំនិញ (POS) ឬហុចប័ណ្ណ EBT របស់លោកអ្នកទៅឱ្យអ្នកគិតប្រាក់ ។

**ជំហានទី3** ចុចបញ្ចូលលេខសម្ងាត់ (PIN) បួនខ្ទង់របស់លោកអ្នក ទៅលើបន្ទះលេខចុច ។ ម៉ាស៊ីននឹងបង្ហាញសញ្ញា **** ជាជំនួសលេខដែលលោកអ្នកចុច ។

**ជំហានទី4** សូមចុចពាក្យ “ENTER” ។

**ជំហានទី5** អ្នកគិតប្រាក់ចុចបញ្ចូលចំនួនតម្លៃជាប័ណ្ណទិញម្ហូប ។ បើសិនជាចំនួនទឹកប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ “OK” ឬពាក្យ “YES” ។

**ជំហានទី6** លោកអ្នកនឹងទទួលសំណៅបង្កាន់ដៃបោះពុម្ពមួយច្បាប់បង្ហាញ:

- ឈ្មោះនិងអាសយដ្ឋានហាងទំនិញ
- ចំនួនប្រាក់ដែលលោកអ្នកបានទិញ
- ចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយនៃគណនីជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក

**ជំហានទី7** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួននៅសល់បន្ទាប់ពីចំណាយសំរាប់លោកអ្នកទៅទិញម្ហូបអាហារនៅពេលក្រោយ ។

សូមចងចាំថា គេមិនអាចគិតថ្លៃឈ្នួលសំរាប់ការប្រើជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក និងលោកអ្នកមិនអាចដកយកប្រាក់ ឬលុយអាប់មកវិញពី គណនីជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នកឡើយ ។

នៅពេលដែលលោកអ្នកប្រើប័ណ្ណ EBT របស់លោកអ្នក ខណ្ឌមិនអាចដឹងថាលោកអ្នកទិញមុខរបស់អ្វីឡើយ ។

## ដើម្បីទិញមុខទំនិញក្រៅពីម្ហូបអាហារនៅតាមម៉ាស៊ុន POS :

លោកអ្នកត្រូវដឹងអំពីចំនួននៅសល់ក្រោយពីការចំណាយរបស់លោកអ្នក! សូមផែកមើលបង្កាន់ដៃចុងក្រោយ ឬទូរស័ព្ទទៅផ្នែកបំរើអតិថិជននៅមុនពេលទិញទំនិញ ឬលោកអ្នកអាចឆែកមើលចំនួននៅសល់ក្រោយពីការចំណាយតាមប្រព័ន្ធអ៊ិនធឺណិត www.ebt.ca.gov ។

**ជំហានទី1** ជ្រើសរើសយកមុខទំនិញក្រៅពីម្ហូបអាហាររបស់លោកអ្នក ហើយនាទៅកាន់ជួរគិតប្រាក់ ។

**ជំហានទី2** ឆូតប័ណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីនចំណុចលក់ទំនិញ (POS) ឬហុចប័ណ្ណ EBT របស់លោកអ្នកទៅឱ្យអ្នកគិតប្រាក់ ។

**ជំហានទី3** ចុចបញ្ចូលលេខសម្ងាត់ (PIN) បួនខ្ទង់របស់លោកអ្នក ទៅលើបន្ទះលេខចុច ។ ម៉ាស៊ីននឹងបង្ហាញសញ្ញា **** ជាជំនួសលេខដែលលោកអ្នកចុច ។

**ជំហានទី4** សូមចុចពាក្យ “ENTER” ។

**ជំហានទី5** ប្រាប់អ្នកគិតប្រាក់ថាលោកអ្នកមានបំណងដកយកប្រាក់ខ្លះ ។

**ជំហានទី6** អ្នកគិតប្រាក់ចុចបញ្ចូលចំនួននៃប្រាក់ជំនួយដែលត្រូវដកយកពីគណនីរបស់លោកអ្នក(គឺជាចំនួនដូចគ្នាទៅនឹងចំនួនដែលលោកអ្នកទិញ ឬក៏ច្រើនជាងបើសិនជាលោកអ្នកចង់ដកយកប្រាក់មួយចំនួន) ។ បើសិនជាចំនួនទឹកប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ “OK” ឬពាក្យ “YES” ។

**ជំហានទី7** លោកអ្នកនឹងទទួលសំណៅបង្កាន់ដៃបោះពុម្ពមួយច្បាប់បង្ហាញ:

- ឈ្មោះនិងអាសយដ្ឋានហាងទំនិញ
- ចំនួនទិញជាប្រាក់សុទ្ធដែលលោកអ្នកបានទិញ និង/ឬដកយក
- ចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយនៃគណនីប្រាក់ជំនួយរបស់លោកអ្នក

**ជំហានទី8** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួននៅសល់បន្ទាប់ពីចំណាយសំរាប់លោកអ្នកទៅទិញទំនិញនៅពេលក្រោយ ។

## ដើម្បីដកយកប្រាក់នៅតាមម៉ាស៊ីន POS :

លោកអ្នកត្រូវដឹងអំពីចំនួននៅសល់ក្រោយពីការចំណាយរបស់លោកអ្នក! សូមឆែកមើលបង្កាន់ដៃចុងក្រោយ ឬទូរស័ព្ទទៅផ្នែកបំរើអតិថិជននៅមុនពេលទៅហាងទំនិញ ឬលោកអ្នកអាចឆែកមើលចំនួននៅសល់ក្រោយពីការចំណាយតាមប្រព័ន្ធអ៊ិនធឺណិត www.ebt.ca.gov ។

**ជំហានទី1** សូមសាកសួរអ្នកគិតប្រាក់នៃហាងទំនិញថាតើលោកអ្នកអាចដកយកប្រាក់ជំនួយនៅហាងនោះ និងតើគេគិតថ្លៃឈ្នួលឬទេ ។

**ជំហានទី2** ឆូតបណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីនចំណុចលក់ទំនិញ (POS) ឬហុចបណ្ណ EBT របស់លោកអ្នកទៅឱ្យអ្នកគិតប្រាក់ ។

**ជំហានទី3** ចុចបញ្ចូលលេខសម្ងាត់ (PIN) បួនខ្ទង់របស់លោកអ្នក ទៅលើបន្ទះលេខចុច ។ ម៉ាស៊ីននឹងបង្ហាញសញ្ញា **** ជាជំនួសលេខដែលលោកអ្នកចុច ។

**ជំហានទី4** សូមចុចពាក្យ “ENTER” ។

**ជំហានទី5** ប្រាប់អ្នកគិតប្រាក់អំពីចំនួនប្រាក់ដែលលោកអ្នកចង់បាន ។

**ជំហានទី6** អ្នកគិតប្រាក់ចុចបញ្ចូលចំនួននៃប្រាក់ជំនួយដែលត្រូវដកយកពីគណនីរបស់លោកអ្នក ។ បើសិនជាចំនួនទឹកប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ “OK” ឬពាក្យ “YES” ។

**ជំហានទី7** លោកអ្នកនឹងទទួលសំណៅបង្កាន់ដៃបោះពុម្ពមួយច្បាប់បង្ហាញ:

- ឈ្មោះនិងអាសយដ្ឋានហាងទំនិញ
- ចំនួនទិញជាប្រាក់ដែលលោកអ្នកបានដកយក
- ចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយនៃគណនីប្រាក់ជំនួយរបស់លោកអ្នក

**ជំហានទី8** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួននៅសល់បន្ទាប់ពីចំណាយសំរាប់លោកអ្នកទៅទិញទំនិញនៅពេលក្រោយ ។

**សូមចងចាំថា លោកអ្នកមិនអាចដកយកប្រាក់ពីគណនីបណ្ណទិញម្ហូបរបស់លោកអ្នកបានឡើយ ។**

# តើគេនឹងធ្វើយ៉ាងណាបើសិនជាម៉ាស៊ីន POS ប្រើការមិនបាន


OFFLINE FOOD STAMP BENEFIT VOUCHER

No. 3079351

Important! Vouchers must be entered or cleared on the POS device (or mailed within 10 days if non-electronic) within 15 days of the sale or funds will not be reimbursed.

Card Number

Print Cardholder Name

Cardholder Signature Date

In signing this voucher, I believe that food stamp benefit funds are available for the full amount of this transaction.

This voucher will be rejected if information in this section has been altered.

Trans. Date/Time

Approval Number

Store FNS Number

Purchase Amount

☐ Purchase ☐ Refund

Merchant ID

Print Store Name

Store Address

Store City/State/Zip Code

Store Supervisor/Clerk Signature

FNS regulations prohibit representation of this voucher by merchant if voice authorization was denied.

Date Entered ___/___/___ Operator's initials

White – Client/Customer Copy Yellow – Merchant Copy Pink – Non-Electronic Retailer Mail-In Copy to Retail Support Operations

NOTE: Electronic Retailers to Retain the Pink copy

បើសិនជាលោកអ្នកមានបំណងចង់ទិញម្ហូបអាហារដែលលោកអ្នកមានសិទ្ធិទិញ ហើយម៉ាស៊ីន POS ប្រើការមិនបាន ឬក្នុងហាងទំនិញមិនមានម៉ាស៊ីន POS អ្នកគិតប្រាក់នឹងបំពេញថ្លៃទិញនៅលើក្រដាសបណ្ណទិញម្ហូបមួយសន្លឹក ។ អ្នកលក់ទំនិញខ្លះដូចជា អ្នកលក់ទំនិញតាមរថយន្តឥតមានម៉ាស៊ីន POS ទេ ។ អ្នកគិតប្រាក់នឹងចម្លងយកលេខបណ្ណ EBT របស់លោកអ្នក ហើយនិងចំនួនដែលលោកអ្នកចំណាយ ។ សូមកុំឱ្យលេខសម្ងាត់ PIN របស់លោកអ្នកទៅអ្នកគិតប្រាក់ ។ អ្នកគិតប្រាក់នឹងទូរស័ព្ទសាកសួរថាតើលោកអ្នកមានចំនួនប្រាក់គ្រប់គ្រាន់ក្នុងគណនីដើម្បីទិញម្ហូបអាហារនោះឬទេ ។ បើសិនជាលោកអ្នកមានចំនួនប្រាក់គ្រប់គ្រាន់នៅក្នុងគណនីរបស់លោកអ្នក គេនឹងសុំឱ្យលោកអ្នកចុះហត្ថលេខានៅលើបណ្ណទិញម្ហូបនោះ ហើយលោកអ្នកនឹងទទួលសន្លឹកបង្កាន់ដៃចម្លងមួយច្បាប់ ។ គឺជាការសំខាន់ណាស់ដែលលោកអ្នកត្រូវរក្សាទុកបង្កាន់ដៃនេះដើម្បីដកចំនួនដែលលោកអ្នកបានចំណាយចេញពីចំនួននៅសល់បន្ទាប់ពីចំណាយដែលមាននៅលើបង្កាន់ដៃ EBT ចុងក្រោយរបស់លោកអ្នក ។ ចំនួននេះគឺជាចំនួនដែលលោកអ្នកមានក្នុងពេលបច្ចុប្បន្ននៅក្នុងគណនីរបស់លោកអ្នក ។

**លោកអ្នកមិនអាចប្រើបណ្ណទិញម្ហូបអាហារដើម្បីដកយកប្រាក់ពីគណនីប្រាក់ជំនួយរបស់លោកអ្នកបានឡើយ ។**

# របៀបប្រើបណ្ណ EBT របស់លោកអ្នក នៅតាមម៉ាស៊ីន ATM

**ជំហានទី1** ស៊កឬឆូតបណ្ណរបស់លោកអ្នកទៅក្នុងម៉ាស៊ីន ATM ។

**ជំហានទី2** ចុចបញ្ចូលលេខសម្ងាត់ PIN ដែលមានបួនលេខរបស់លោកអ្នក នៅលើបន្ទះចុចលេខ រួចចុចពាក្យ “OK” ឬពាក្យ “ENTER” ។

**ជំហានទី3** ជ្រើសរើសពាក្យដកយកប្រាក់ “WITHDRAW CASH” រួចមក ជ្រើសរើសពាក្យគណនីសែក “CHECKING” ។ (ម៉ាស៊ីន ATM ខ្លះប្រើពាក្យផ្សេងពីនេះ) ។



**ជំហានទី4** សូមចុចយកចំនួនប្រាក់ដុល្លារដែលលោកអ្នកចង់ដក ជាចំនួនប្រាក់ដុំ (ជាឧទាហរណ៍ ចំនួន $20 ឬ $200 ឬចំនួនឯទៀត) ។ សន្លឹកប្រាក់១០ដុល្លារ និង២០ដុល្លារ ជាសន្លឹកប្រាក់តូចជាងគេ ដែលធម្មតាគេបានប្រើ ។

**ជំហានទី5** ម៉ាស៊ីន ATM ខ្លះនឹងគិតថ្លៃឈ្នួលបន្ថែម ។ បើសិនជាមានថ្លៃឈ្នួលបន្ថែម ម៉ាស៊ីន ATM នោះនឹងបង្ហាញនៅលើកញ្ចក់ប្រាប់លោកអ្នកអំពីចំនួននោះ ។ បើសិនជាលោកអ្នកយល់ព្រម សូមចុចពាក្យបន្ត “CONTINUE” ។ បើសិនជាលោកអ្នកមិនចង់បង់ថ្លៃឈ្នួលទេ លោកអ្នកអាចចុចពាក្យលុបចោល “CANCEL” ។

**ជំហានទី6** ម៉ាស៊ីន ATM នឹងផ្តល់ប្រាក់ និងបង្កាន់ដៃជូនលោកអ្នក ។

**ជំហានទី7** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយ សំរាប់លោកអ្នកត្រូវការប្រាក់នៅពេលក្រោយ ។

**សូមចងចាំថា លោកអ្នកមិនអាចដកយកប្រាក់ឬប្រាក់អាប់មកវិញ ពីគណនីបណ្ណទិញម្ហូបរបស់លោកអ្នកបានឡើយ ។**

## ព័ត៌មានសំខាន់ៗសំរាប់សុវត្ថិភាពក្នុងការប្រើម៉ាស៊ីន ATM

- ប្រុងប្រៀបបណ្ណរបស់លោកអ្នកឱ្យបានរួចជាស្រេច ។
- ជ្រើសរើសយកកន្លែងម៉ាស៊ីន ATM ដែលមានភ្លើងបំភ្លឺគ្រប់គ្រាន់ ដែលលោកអ្នកមានអារម្មណ៍សុវត្ថិភាព(ដូចជានៅក្នុងហាងទំនិញជាដើម) ។
- ឈរយ៉ាងណាដើម្បីកុំឱ្យនរណាម្នាក់អាចមើលឃើញលេខសម្ងាត់ PIN ដែលលោកអ្នកប្រើ ។
- រាប់ប្រាក់របស់លោកអ្នក បើសិនជាលោកអ្នកមានអារម្មណ៍ថាមានសុវត្ថិភាព ។
- ទុកប្រាក់ បណ្ណ និងបង្កាន់ដៃរបស់លោកអ្នកជាប្រញាប់ ។

# របៀបថែរក្សាបណ្ណ EBT របស់លោកអ្នក

**មិនត្រូវ** រក្សាទុកបណ្ណនិងលេខសម្ងាត់របស់លោកអ្នកនៅជាមួយគ្នាឡើយ ។

**មិនត្រូវ** ធ្វើឱ្យខូច ឬបត់បណ្ណរបស់លោកអ្នកឡើយ ។

**មិនត្រូវ** សរសេរលើឬធ្វើឱ្យមានស្នាមឆូតលើបន្ទះពណ៌ខ្មៅខាងក្រោយនៃបណ្ណ ។

**មិនត្រូវ** ដាក់បណ្ណរបស់លោកអ្នកនៅជិតមេដែក ទូរទស្សន៍ ម៉ាស៊ីនចាក់ឌីវីឌី ម៉ាស៊ីនចាក់ស៊ីឌី ម៉ាស៊ីនចាក់កាសែតចំរៀងឬកាសែតវីឌីអូឡើយ ។

**មិនត្រូវ** ទុកបណ្ណរបស់លោកអ្នកនៅហាលថ្ងៃ ដូចជាទុកពីលើកន្លែងកុងទ័រខាងក្រោមកញ្ចក់មុខរថយន្ត ដែលធ្វើឱ្យបណ្ណទៅជាកោង ប្រើការមិនបាន ។

**មិនត្រូវ** ដាក់ចោលបណ្ណរបស់លោកអ្នកមិនប្រយ័ត្ន–តែងតែទុកបណ្ណរបស់លោកអ្នកនៅកន្លែងដែលមានសុវត្ថិភាពបន្ទាប់ពីបានប្រើរួច ។

**មិនត្រូវ** បោះចោលបណ្ណរបស់លោកអ្នកឡើយ–លោកអ្នកនឹងប្រើបណ្ណដដែលនេះជារៀងរាល់ខែ ឱ្យតែលោកអ្នកនៅទទួលជំនួយ ។ ម្យ៉ាងទៀត លោកអ្នកអាចប្រើបណ្ណ EBT របស់លោកអ្នកនៅពេលណាដែលលោកអ្នកឃើញសញ្ញា Quest® ទូទាំងរដ្ឋកាលីហ្វ័រនីញ៉ា និងទូទាំងប្រទេស ។

**មិនត្រូវ** បោះចោលបណ្ណរបស់លោកអ្នកឡើយបើសិនជាលោកអ្នកប្តូរទីលំនៅពីព្រោះលោកអ្នកអាចមាននៅសល់ជំនួយនៅក្នុងបណ្ណរបស់លោកអ្នក ។

បើសិនជាលោកអ្នកបាត់បណ្ណ ឬក៏បណ្ណត្រូវគេលួច សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជនជាបន្ទាន់ ។ ពួកគេនឹងធ្វើឱ្យបណ្ណដែលបាត់នោះដកប្រាក់មិនបាន ហើយនិងជំរាបលោកអ្នកអំពីរបៀបទទួលបណ្ណថ្មី ។ ជាការសំខាន់ណាស់ដែលលោកអ្នកទូរស័ព្ទទៅផ្នែកបំរើអតិថិជនជាបន្ទាន់ទៅតាមលទ្ធភាព! វាអាចត្រូវការពេលបីថ្ងៃធ្វើការ ដើម្បីទទួលបណ្ណថ្មីមួយទៀត ។

# ថ្លៃឈ្នួលគិតបន្ថែម

ថ្លៃឈ្នួលគិតបន្ថែម គឺជាថ្លៃដែលហាងទំនិញឬធនាគារខ្លះអាចគិតថ្លៃបន្ថែមពីលោកអ្នកនៅក្នុងពេលនីមួយៗដែលលោកអ្នកដកយកប្រាក់ជំនួយជាមួយបណ្ណ EBT របស់លោកអ្នក ។ នៅមុនពេលលោកអ្នកប្រើបណ្ណ សូមស្វែងរកនូវសេចក្តីប្រកាសប្រាប់អំពីការគិតថ្លៃឈ្នួលបន្ថែមនៅលើកញ្ចក់ ATM ឬនៅលើផ្លាកសញ្ញានៅក្បែរម៉ាស៊ីន POS នៅក្នុងហាងទំនិញ ។ បើសិនជាលោកអ្នកមិនចង់បង់ថ្លៃឈ្នួលគិតបន្ថែមទេ លោកអ្នកអាចជ្រើសរើសកន្លែងដទៃទៀត ។ លោកអ្នកអាចសាកសួរការិយាល័យផ្តល់ជំនួយសាធារណៈក្នុងតំបន់របស់លោកអ្នកថាកន្លែងណាដែលលោកអ្នកអាចដកយកប្រាក់របស់លោកអ្នកដោយមិនបាច់បង់ថ្លៃឈ្នួលគិតបន្ថែម ។

# ថ្លៃឈ្នួលប្រើបណ្ណ

ថ្លៃឈ្នួលប្រើបណ្ណគឺជាថ្លៃឈ្នួលបន្ថែមដែលគេអាចឱ្យលោកអ្នកបង់សំរាប់ការដកប្រាក់តាមម៉ាស៊ីន ATM ។ លោកអ្នកត្រូវបានអនុញ្ញាតឱ្យដកយកប្រាក់បានបួនដងនៅក្នុងខែនីមួយៗពីម៉ាស៊ីន ATM ឬ POS ដោយមិនអស់ថ្លៃឈ្នួល ។ បន្ទាប់ពីបានដកប្រាក់បួនដងហើយ គេនឹងគិតថ្លៃឈ្នួល៨០សេនដកយកពីគណនីរបស់លោកអ្នក សំរាប់ការប្រើបណ្ណជាបន្ថែមម្តងៗនៅតាមម៉ាស៊ីន ATM ។ គេមិនបានរាប់បញ្ចូលជាផ្នែកមួយនៃការដកប្រាក់ទាំងបួនដងទេ ចំពោះការទិញទំនិញនិងការទិញដោយមានដកយកប្រាក់នោះ ។ គេនឹងមិនគិតថ្លៃឈ្នួលប្រើបណ្ណចំពោះការប្រើបណ្ណរបស់លោកអ្នកនៅតាមម៉ាស៊ីន POS ។ បើសិនជាលោកអ្នកប្រើបណ្ណដើម្បីឆែកមើលចំនួនទឹកប្រាក់ដែលមានសំរាប់ចំណាយនៅតាមម៉ាស៊ីន ATM លោកអ្នកនឹងត្រូវបង់ថ្លៃឈ្នួល២៥សេន ។

# ការដាក់ប្រាក់បញ្ញាលដោយផ្ទាល់

នៅតាមខណ្ឌភាគច្រើន លោកអ្នកអាចជ្រើសរើសឱ្យគេដាក់បញ្ញាលប្រាក់ជំនួយរបស់លោកអ្នកជារៀងរាល់ខែ ទៅក្នុងគណនីផ្ទាល់ខ្លួននៃធនាគារឬធនាគារសហជីពបច្ចុប្បន្នរបស់លោកអ្នក ជាជំនួសប្រើប័ណ្ណ EBT ។ សូមសាកសួរអ្នកកាន់សំណុំរឿងរបស់លោកអ្នកដើម្បីឱ្យបានដឹងថាតើ ការដាក់ប្រាក់បញ្ញាលដោយផ្ទាល់មាននៅក្នុងខណ្ឌរបស់លោកអ្នកឬទេ និងដើម្បីសាកសួរពត៌មានបន្ថែមទៀតអំពីការដាក់ប្រាក់បញ្ញាលដោយផ្ទាល់នេះ ។

## នៅពេលណាដែលត្រូវទូរស័ព្ទទៅ ផ្នែកបំរើអតិថិជនតាមលេខឥតបង់ប្រាក់ 1-877-328-9677

នេះគឺជាការទូរស័ព្ទដោយឥតបាច់បង់ប្រាក់ ។

ផ្នែកផ្តល់ជំនួយអតិថិជនបើកធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍ ដើម្បីឆ្លើយនូវសំណួរណាមួយដែលលោកអ្នកអាចមានអំពីប័ណ្ណ EBT របស់លោកអ្នក ។ នៅពេលទូរស័ព្ទ លោកអ្នកនឹងជួបជាមួយម៉ាស៊ីនឆ្លើយតបដោយស្វ័យប្រវត្តិ ហើយសំណួររបស់លោកអ្នកភាគច្រើនអាចឆ្លើយប្រាប់បានដោយមិនចាំបាច់ជួបនិយាយជាមួយអ្នកតំណាងផ្នែកបំរើអតិថិជន ។ ចម្លើយទាំងនេះអាចមានផ្តល់ជូនជាភាសា អង់គ្លេស អេស្ប៉ាញ៉ុល អាមីុនៀនខាងកើត ខ្មែរ ចិន ហ្វាស៊ីម៉ុង លាវ រ៉ុស្ស៊ី និងវៀតណាម ។

សូមទូរស័ព្ទ បើសិនជា :

- លោកអ្នកបាត់ប័ណ្ណ ឬត្រូវគេលួចប័ណ្ណរបស់លោកអ្នក ។
- ប័ណ្ណរបស់លោកអ្នកខូចប្រើការលែងកើត ។
- លោកអ្នកមានបំណងចង់ប្តូរលេខសម្ងាត់ PIN របស់លោកអ្នក ពីព្រោះលោកអ្នកភ្លេចលេខ ឬមាននរណាម្នាក់ដឹងលេខសម្ងាត់ PIN របស់លោកអ្នក ។ ការិយាល័យផ្តល់ជំនួយសារធារណៈរបស់លោកអ្នកអាចជួយប្តូរលេខសម្ងាត់ PIN របស់លោកអ្នកបាន ។
- លោកអ្នកមានបំណងចង់ដឹងអំពីចំនួនប្រាក់ដែលនៅសល់ក្នុងគណនីរបស់លោកអ្នក ។
- លោកអ្នកត្រូវបានគេគិតប្រាក់ថ្លៃទិញ ប៉ុន្តែលោកអ្នកមិនបានទទួលទំនិញ ឬក៏គេគិតប្រាក់លោកអ្នកលើសពីចំនួនតម្លៃដែលលោកអ្នកបានទិញ ។
- លោកអ្នកមានសំណួរ ឬបញ្ហាផ្សេងទៀត ។

## ធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍
## 1-877-328-9677 ឬ

**តាមគេហទំព័រអ៊ិនធឺណិត www.ebt.ca.gov**

**TTY: 1-800-735-2929 (ប្រព័ន្ធទូរស័ព្ទបញ្ជូនបន្តសំរាប់លោកអ្នកដែលមានភាពពិការក្នុងការស្តាប់ និងការនិយាយ)**

# ពេលណាដែលលោកអ្នកនឹង ទទួលជំនួយរបស់លោកអ្នក

ថ្ងៃនៃខែដែលលោកអ្នកនឹងទទួលបណ្ណទិញម្ហូបនិង/ឬប្រាក់ជំនួយរបស់លោកអ្នក គឺអាស្រ័យទៅលើលេខចុងក្រោយនៃលេខសំណុំរឿងរបស់លោកអ្នក ។

## ជំនួយបណ្ណទិញម្ហូប

| បើសិនជាលេខចុងក្រោយនៃលេខសំណុំរឿងរបស់លោកអ្នកគឺ: | បណ្ណទិញម្ហូបរបស់លោកអ្នកនឹងមានផ្តល់ជូននៅ: |
|---|---|
| 1 | ថ្ងៃទី១ នៃខែ |
| 2 | ថ្ងៃទី២ នៃខែ |
| 3 | ថ្ងៃទី៣ នៃខែ |
| 4 | ថ្ងៃទី៤ នៃខែ |
| 5 | ថ្ងៃទី៥ នៃខែ |
| 6 | ថ្ងៃទី៦ នៃខែ |
| 7 | ថ្ងៃទី៧ នៃខែ |
| 8 | ថ្ងៃទី៨ នៃខែ |
| 9 | ថ្ងៃទី៩ នៃខែ |
| 0 | ថ្ងៃទី១០ នៃខែ |

## ប្រាក់ជំនួយ

| បើសិនជាលេខចុងក្រោយនៃលេខសំណុំរឿងរបស់លោកអ្នកគឺ : | ប្រាក់ជំនួយរបស់លោកអ្នកនឹងមានផ្តល់ជូននៅ : |
|---|---|
| 1, 2, 3 | ថ្ងៃទី១ នៃខែ |
| 4, 5, 6, 7 | ថ្ងៃទី២ នៃខែ |
| 8, 9, 0 | ថ្ងៃទី៣ នៃខែ |

- ជំនួយមានផ្តល់ជូននៅថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សំរាក ។
- ចំនួនប្រាក់នៅសល់ក្រោយពីចំណាយរបស់លោកអ្នកនៅពេលដាច់ខែ ត្រូវបានបូកទៅលើចំនួនទឹកប្រាក់សំរាប់ខែបន្ទាប់ ។

សូមកត់ទុកថ្ងៃដែលបណ្ណទិញម្ហូបរបស់លោកអ្នកនឹងត្រូវបានគេដាក់បញ្ចូលទៅក្នុងគណនីរបស់លោកអ្នក :

____________________________________

(ថ្ងៃទី១ទៅទល់នឹងថ្ងៃទី១០នៃខែ)

សូមកត់ទុកថ្ងៃដែលប្រាក់ជំនួយរបស់លោកអ្នកនឹងត្រូវបានគេដាក់បញ្ចូលទៅក្នុងគណនីរបស់លោកអ្នក :

____________________________________

(ថ្ងៃទី១, ថ្ងៃទី២, ថ្ងៃទី៣នៃខែ)

# របស់ដែលលោកអ្នកត្រូវចងចាំ

## អំពីបណ្ណ/លេខសម្ងាត់ PIN របស់លោកអ្នក

- បើសិនជាលោកអ្នកបាត់បណ្ណ ឬត្រូវគេលួចបណ្ណរបស់លោកអ្នក សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជនជាបន្ទាន់ ។
- សូមថែរក្សាបណ្ណរបស់លោកអ្នកឱ្យបានល្អ ។
- សូមរក្សាទុកបណ្ណរបស់លោកអ្នកនៅក្នុងកន្លែងមានសុវត្ថិភាព ។
- សូមកុំឱ្យអ្នកណាម្នាក់ប្រើបណ្ណរបស់លោកអ្នកដោយគ្មានការអនុញ្ញាត ។
- លោកអ្នកប្រើលេខសម្ងាត់ PIN របស់លោកអ្នករៀងរាល់ពេលដែលលោកអ្នកប្រើបណ្ណរបស់លោកអ្នក លើកលែងតែនៅពេលណាដែលលោកអ្នកប្រើសន្លឹកក្រដាសបណ្ណទិញម្ហូប ។
- សូមកុំទុកចោលបណ្ណរបស់លោកអ្នកនៅតាមម៉ាស៊ីន ATM ឬ POS ឱ្យសោះ ។
- សូមទូរស័ព្ទទៅការិយាល័យផ្តល់ជំនួយសាធារណៈរបស់លោកអ្នក បើសិនជាលោកអ្នកផ្លាស់ប្តូរទីលំនៅ ។ លោកអ្នកនឹងអាចប្រើជំនួយរបស់លោកអ្នកនៅក្នុងខណ្ឌថ្មីរបស់លោកអ្នក ។

## អំពីចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយរបស់លោកអ្នក

- សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកបានដឹងចំនួនប្រាក់នៅសល់បន្ទាប់ពីការចំណាយនៅក្នុងគណនីរបស់លោកអ្នក ។
- សូមឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីការចំណាយក្នុងគណនីរបស់លោកអ្នកនៅមុនពេលលោកអ្នកទៅផ្សារទិញទំនិញ ។
- លោកអ្នកអាចដកយកប្រាក់ទាំងអស់ដែលមាននៅក្នុងគណនីរបស់លោកអ្នកក្នុងពេលមួយថ្ងៃនៅតាមម៉ាស៊ីន ATM ឬម៉ាស៊ីន POS ។ ក៏ប៉ុន្តែយោងទៅតាមការកំណត់អាចដកប្រាក់បាននៃម៉ាស៊ីន ATM ឬម៉ាស៊ីន POS ពីព្រោះលោកអ្នកអាចត្រូវការដកហូតច្រើនជាងម្តង ។
- លោកអ្នកអាចឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយនៅក្នុងគណនីរបស់លោកអ្នកតាមអ៊ីនធឺណិត www.ebt.ca.gov ។

## អំពីម៉ាស៊ីន POS

- ប្រើម៉ាស៊ីន POS ដើម្បីទិញម្ហូបអាហារជាមួយគណនីបណ្ណទិញម្ហូប ឬដើម្បីដកយកប្រាក់ជំនួយរបស់លោកអ្នក ។
- គេនឹងមិនដែលគិតថ្លៃឈ្នួលណាមួយ សំរាប់ការប្រើជំនួយបណ្ណទិញម្ហូបរបស់លោកអ្នកឡើយ ។
- ហាងលក់ទំនិញអាចគិតថ្លៃឈ្នួលបន្ថែមចំពោះការដកហូតយកប្រាក់ បើសិនជាលោកអ្នកមិនបានទិញទំនិញ ។ សូមសាកសួរហាងទំនិញអំពីច្បាប់ហាង ។

## អំពីម៉ាស៊ីន ATM

- ប្រើម៉ាស៊ីន ATM ដើម្បីដកយកប្រាក់ជំនួយ ។
- ម៉ាស៊ីន ATM ខ្លះគិតថ្លៃឈ្នួលបន្ថែម ។ សូមសាកសួរការិយាល័យផ្តល់ជំនួយសាធារណៈក្នុងតំបន់របស់លោកអ្នក ថាកន្លែងណាដែលលោកអ្នកអាចប្រើបណ្ណដោយមិនបាច់បង់ថ្លៃឈ្នួលបន្ថែម ។
- បន្ទាប់ពីលោកអ្នកបានដកប្រាក់ចំនួនបួនដងក្នុង១ខែនៅតាមម៉ាស៊ីន ATM ឬម៉ាស៊ីន POS ការដកប្រាក់ជាបន្ថែមក្នុងមួយលើកៗតាមម៉ាស៊ីន ATM នឹងត្រូវបង់ថ្លៃឈ្នួល ៨០សេន ។

ស្របទៅតាមច្បាប់សហព័ន្ធនិងច្បាប់ក្រសួងកសិកម្មសហរដ្ឋអាមេរិក (U.S. Department of Agriculture) ស្ថាប័ននេះត្រូវបានហាមប្រាមអំពីការប្រកែរប្រកាន់ដោយសារតែមូលហេតុពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិ ភេទ អាយុ សាសនា ជំនឿនយោបាយ ឬ ភាពពិការ ។ ដើម្បីធ្វើពាក្យបណ្តឹងអំពីការប្រកែប្រកាន់ សូមសរសេរទៅ : USDA, Director, Office of Civil Rights, 1400 Independence Avenue, S.W., Washington, D.C. 20250-9410 ឬទូរស័ព្ទ (800) 795-3272 (សម្លេង) ឬ (202) 720-6382 (TTY) (សំរាប់អ្នកពិការស្តាប់មិនឮឬគ) ។ USDA គឺជាក្រសួងផ្តល់កិច្ចជួយនិងការងារស្មើៗគ្នា ។

STATE OF CALIFORNIA
HEALTH AND HUMAN SERVICES AGENCY
DEPARTMENT OF SOCIAL SERVICES

PUB 388 (Cambodian) (5/09)